# ទំព័រដើម

នៅក្នុងការប្រជុំប្រចាំខែមួយ ខ្ញុំអង្គុយក្នុងចំណោមបុគ្គលិកដទៃទៀត ដើម្បីស្ដាប់អ្នកដទៃឡើងនិយាយដូចសព្វដង។ លើកនេះ ហាក់ដូចជាចម្លែកបន្តិច ព្រោះ CEO របស់ខ្ញុំ ជាអ្នកបើកឆាកនិយាយមុនគេ។ រាល់ដង គាត់អង្គុយស្ដាប់គេនិយាយឲ្យចប់សិន ទើបគាត់បញ្ចេញវាចារបស់គាត់។ ខ្ញុំមិនដឹងថាគាត់មានអ្វីសំខាន់ដែលត្រូវប្រាប់បុគ្គលិកទេ ក្រៅពីប្រកាសបិទក្រុមហ៊ុនចោល។ វាមិនដូចការគិតក្នុងផ្លូវអាក្រក់របស់ខ្ញុំទេ។ គាត់លើកពីបញ្ហាបុគ្គលិកធ្វើការមិនត្រូវគ្នាមកនិយាយ។

ខ្ញុំគ្មានអ្វីភ្ញាក់ផ្អើលទេ នៅពេលដឹងថា បុគ្គលិកដទៃមិនត្រូវគ្នា ប៉ុន្តែសម្រាប់គាត់គឺជារឿងធំ។ បុគ្គលិកមិនត្រូវគ្នា ធ្វើឲ្យការងារទៅមុខយឺតជាងការកំណត់របស់គាត់។ អ្នកជំនួញ ត្រូវតែបារម្ភពីរឿងនេះ។ គាត់និយាយបានមួយសន្ទុះ គាត់ក៏ផ្ដល់ឱកាសឲ្យបុគ្គលិកស្រីម្នាក់ឡើងនិយាយម្ដង ព្រោះរឿងនោះទាក់ទងនឹងម្នាក់ស្រីនោះ។ ខ្ញុំនៅអង្គុយស្ដាប់ដដែល ព្រោះខ្ញុំចង់ដឹងថា មានរឿងអ្វីឲ្យប្រាកដ។

ក្រោយពីស្ដាប់រឿងដែលគេនិយាយហើយ ទើបខ្ញុំដឹងថា ម្នាក់ស្រីនោះមានជម្ងឺមហារីកដំណាក់ទីបី។ មូលហេតុនេះ គឺអាចឲ្យគាត់មានលេសយករួចខ្លួនពីការងារយឺតយ៉ាវរបស់គាត់បានទាំងអស់។ CEO របស់ខ្ញុំជាមនុស្សឆ្លាតណាស់។ គាត់យករឿងនេះមកនិយាយដើម្បីធ្វើឲ្យបុគ្គលិកចេះអាណិតស្រលាញ់គ្នា ព្រោះគាត់ដឹងថា នៅពេលមានអ្នកណាម្នាក់ជិតស្លាប់ មនុស្សគ្រប់គ្នានឹងចាប់ផ្ដើមធ្វើល្អជាមួយម្នាក់នោះ។ ប៉ុន្តែនៅចុងសាច់រឿងរបស់ម្នាក់ស្រីនោះ គាត់បាននិយាយថា គាត់ជាពីជម្ងឺមហារីកនោះហើយ។ គាត់ថែមទាំងនិយាយទៀតថា នេះជាការប្រទានពរពីព្រះជាម្ចាស់របស់គាត់។

អ្នកដទៃស្ដាប់ហើយ នៅស្ងៀម បញ្ចេញទឹកមុខស្រងូតស្រងាត់។ ខ្លះទៀតមកទះស្មារបស់បុគ្គលិកស្រីនោះ ដើម្បីផ្ដល់ជាកម្លាំងចិត្ត។ ប៉ុន្តែមានអ្នកខ្លះ ស្ថិតក្នុង

ទឹកមុខមិនជឿ និងមិនចាប់អារម្មណ៍។ ខ្ញុំក៏ស្ថិតក្នុងប៉ុន្មាននាក់នោះដែរ។ ខ្ញុំអត់ឆ្ងល់មិនបាន ព្រោះខ្ញុំមិនឃើញលិខិតពេទ្យច្បាស់លាស់ ហើយជម្ងឺមហារីកប្រភេទអ្វីក៏គាត់មិនបញ្ជាក់ដែរ។ អ្វីដែលខ្ញុំឆ្ងល់ជាងគេ គឺហេតុអ្វីបានជាគាត់មិននិយាយតាំងពីពេលចូលធ្វើការដំបូង ហើយទើបយកមកនិយាយនៅពេលគេរករឿងគាត់ព្រោះធ្វើការមិនទាន់ពេលបែបនេះ? ខ្ញុំមិនបានចម្លើយទេពីរឿងនេះ តែវាធ្វើឲ្យខ្ញុំឆ្ងល់។

ខ្ញុំឆ្ងល់ពីអ្នកដទៃ និងរឿងរ៉ាវដែលកើតនៅជុំវិញខ្លួនខ្ញុំ។ ពេលខ្លះខ្ញុំសួរអ្នកដទៃ ពេលខ្លះ ខ្ញុំរកចម្លើយដោយខ្លួនឯង។ ខ្ញុំមិនប្រាកដថាបានចម្លើយគ្រប់ពេលទេ តែខ្ញុំមានសំណួរគ្រប់ពេល។ សំណួរដែលខ្ញុំនឹកឃើញខ្លះ អាចធ្វើឲ្យអ្នកដទៃខឹងនឹងខ្ញុំ ប៉ុន្តែវាធ្វើឲ្យខ្ញុំពេញចិត្ត។ ខ្ញុំមិនពេញចិត្តនឹងការខឹងរបស់អ្នកដទៃទេ ប៉ុន្តែខ្ញុំពេញចិត្តនឹងខ្លួនឯងដែលរកកន្លែងឆ្ងល់ឃើញ។

ពេលខ្ញុំធ្វើការនៅកាស៊ីណូ ខ្ញុំធ្លាប់សួរស្រីស្អាតម្នាក់ដែលធ្វើការជាមួយគ្នា។ ខ្ញុំឃើញចិញ្ចៀនលើដៃរបស់គាត់ និងពោះកំប៉ោងរបស់គាត់។ ខ្ញុំសួរថា ចិញ្ចៀនហ្នឹងប្ដីរបស់គាត់ជាអ្នកទិញឲ្យមែនទេ? ហើយធ្វើម៉េចបានស្គាល់គ្នាជាមួយប្ដីរបស់គាត់? សំណួរធម្មតាបែបនេះ បែរជាធ្វើឲ្យខ្ញុំរៀនពីអ្វីដែលមនុស្សស្រីចង់បាន នៅថ្ងៃរៀបការទៅវិញ។ ខ្ញុំមិនដឹងថា ក្រោយពេលសួរបែបនេះ គាត់សុខចិត្តឈរនិយាយប្រាប់ខ្ញុំពីរឿងរៀបការរបស់គាត់ទេ។ ខ្ញុំជឿថា មនុស្សជាច្រើនដែលមានរឿងផ្ទាល់ខ្លួន ហើយចង់ឲ្យអ្នកដទៃស្ដាប់ ហេតុនេះបើយើងចេះសួរ យើងនឹងអាចនឹងដឹងរឿងល្អៗក៏ថាបានដែរ។

ចម្ងល់ ធ្វើឲ្យខ្ញុំចាប់អារម្មណ៍លើរឿងគ្រប់យ៉ាង។ វាជាការសំខាន់របស់អ្នកនិពន្ធដែលត្រូវដឹងរឿងឲ្យបានច្រើន ដើម្បីមានអ្វីសរសេរបន្ត។ អ្នកនិពន្ធ ជាអ្នកចាប់អារម្មណ៍លើទាំងតូច ទាំងធំនៅជុំវិញខ្លួន ហើយយកចម្លើយដែលខ្លួនរកឃើញ មកស

រសេរឲ្យបានត្រឹមត្រូវសម្រាប់អ្នកអាន។ អ្នកអាន ជាអ្នកចាំទទួលផលស្រាប់ៗ គ្រាន់តែពេលខ្លះត្រូវចំណាយលុយខ្លះដើម្បីទិញស្នាដៃរបស់គេមកអានប៉ុណ្ណោះ។

សៀវភៅ "រស់ក្នុងចម្ងល់" ជាស្នាដៃថ្មីរបស់ខ្ញុំដែលសរសេរឡើងក្នុងគោលបំណងលើកកម្ពស់ការឆ្ងល់ និងគាំទ្រឲ្យបង្កើតជាទម្លាប់ឆ្ងល់នៅគ្រប់កាលៈទេសៈ។ ខ្ញុំយកអ្វីដែលខ្ញុំឆ្ងល់ មកសរសេរជាសៀវភៅ និងផ្ដល់ជាយោបល់ខ្លះៗដល់អ្នកដែលចង់រៀនឆ្ងល់ដែរ។

ខ្ញុំមិនច្បាស់ថា សៀវភៅមួយក្បាលនេះមានប្រយោជន៍ដល់កម្រិតណាទេ ព្រោះអ្នកអានមានកម្រិតនៃការយល់ដឹង និងចំណង់ចំណូលចិត្តខុសគ្នា។ បើសិនជាមានប្រយោជន៍ ខ្ញុំក៏ពេញចិត្តនឹងអ្វីដែលខ្ញុំបានសរសេរ តែបើគ្មានប្រយោជន៍ ខ្ញុំក៏នៅតែពេញចិត្តដូចគ្នា។ សម្រាប់ខ្ញុំ គ្រប់សៀវភៅ សុទ្ធតែមានប្រយោជន៍សម្រាប់ខ្លួនខ្ញុំជានិច្ច តែដោយសារអ្នកនិពន្ធត្រូវការការវាយតម្លៃពីអ្នកអាន ខ្ញុំមិនអាចកំណត់ភាពមានប្រយោជន៍របស់វាបានទេ។

បើអ្នកទាំងអស់គ្នាឆ្ងល់ថា តើសៀវភៅនេះនឹងសរសេរពីអ្វី អាចអានបន្តទៅមុខទៀតបាន។ ខ្ញុំនឹងព្យាយាមឲ្យអស់ពីលទ្ធភាពដើម្បីពន្យល់ និងលើកជាឧទាហរណ៍ជាក់ស្ដែងសម្រាប់ចំណុចនីមួយៗ។ នៅពេលអាន កុំភ្លេចឆ្ងល់ផង។

ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៨

ហួត សេងគៀ

# ចំណុចទី១
# ការរស់នៅក្នុងចម្ងល់

*"កុំស្មានអ្វីទាំងអស់ ត្រូវសួរសំណួរគ្រប់រឿង។"*
(*ពាក្យបើកឆាករបស់កម្មវិធីផ្សាយជាសម្លេង* THE THINKING ATHEISTS)

ការឆ្ងល់ ជាចរិតធម្មជាតិរបស់មនុស្ស។ នៅពេលក្មេងកើតមក ពួកគេចាប់ផ្តើមឆ្ងល់បន្តិចម្តងពីរឿងគ្រប់យ៉ាង។ ការឆ្ងល់នេះហើយ ដែលធ្វើឱ្យពួកគេដឹងពីរបៀបរស់នៅ ប៉ុន្តែនៅពេលគេធំឡើង សង្គម និងគ្រួសារ ក៏បង្រៀនកុំឱ្យក្មេងឆ្ងល់វិញ។ ក្មេងអាចសួរសំណួរគ្រប់ប្រភេទទៅកាន់ឪពុកម្តាយរបស់ពួកគេ ហើយអាចរំពឹងថានឹងទទួលចម្លើយមកវិញគ្រប់ពេល។ នៅពេលធំដឹងក្តី សំណួរខ្លះនឹងត្រូវឪពុកម្តាយធ្វើពុតជាមិនលឺ ឬស្រែកគំហកមិនឲ្យសួរបន្តទៀត។ ចម្ងល់ពីក្មេង និងចម្ងល់ពេលធំឡើងត្រូវគេទុកជារឿងពីរផ្សេងគ្នា។ យើងអាចនឹងមិនចាប់អារម្មណ៍ថា សង្គម និងគ្រួសារជាអ្នកបំផ្លាញការឆ្ងល់របស់មនុស្ស ប៉ុន្តែវាជាការពិត។

ការរស់នៅក្នុងសង្គម អាចកើតមានបាន បើសិនជាយើងព្រមលះបង់ ភាពជាម្ចាស់ការលើខ្លួនឯង និងលក្ខណៈផ្ទាល់ខ្លួនរបស់យើង។ យើងមិនអាចចូលចំណោមគេចុះនោះទេ បើសិនជាសង្គមរបស់យើងងប់ងល់នឹងជំនឿអ្វីមួយ ហើយខ្លួនយើង មិនជឿតាមគេ។ យើងក៏មិនអាចចូលសង្គមចុះដែរ បើយើងគិតថា ការទិញរបស់មិនចាំបាច់ជារឿងមិនមានប្រយោជន៍ដល់សេដ្ឋកិច្ចសង្គម។ យើងកាន់តែមិនអាចចូលសង្គមបាន បើសិនយើងគិតថា មនុស្សមិនត្រូវការអ្នកដឹកនាំដើម្បីគ្រប់គ្រងការរស់

នៅរបស់ពួកគេ។ ពេលដែលយើងចេះឆ្ងល់ ការគិតរបស់យើងនឹងខុសពីអ្នកដែលមិនចេះឆ្ងល់ ហើយវាធ្វើឲ្យយើងពិបាកនឹងចុះសម្រុងក្នុងសង្គម។

យើងឯកភាពជាមួយសង្គមគ្រប់រឿង។ ការឯកភាពនេះ នាំយើងឱ្យលែងឆ្ងល់ ហើយរស់នៅយ៉ាងរំភើយ ដូចជាពិភពលោកនេះ គ្មានអ្វីដែលត្រូវឆ្ងល់។ យើងគិតថា បើឆ្ងល់ ក៏មិនដឹងបានអីមកវិញ ព្រោះអ្នកដទៃទៀតមិនឆ្ងល់អ្វីផង ហើយគេក៏អាចរស់នៅបានជម្មតា។ យើងមើលគេមើលឯង ហើយធ្វើតាមគេ ព្រោះនេះជារបៀបរស់នៅក្នុងសង្គម។

ក្នុងសង្គមប្រភេទណាក៏ដោយ ក៏តែងតែមានមនុស្សប្រភេទក្រៅសង្គមដែរ។ មនុស្សក្រៅសង្គម អាចបែងចែកជាពីរ គឺល្អ និងមិនល្អ។ មនុស្សក្រៅសង្គមល្អ មើលឃើញចំណុចអាក្រក់របស់សង្គម ហើយគេនឹងមិនចូលរួមនឹងសកម្មភាពទាំងនោះទេ។ ជួនកាល គេមានចិត្តល្អ ឬមានពេលច្រើន គេក៏ជួយដាស់តឿនមនុស្សក្បែរខ្លួនគេទៀតផង។ ពួកគេ ចេះបែងចែកអ្វីល្អ ឬមិនល្អដោយខ្លួនឯង។

ចំណែកមនុស្សក្រៅសង្គមដែលមិនល្អវិញ ច្រើនតែនាំរឿងក្ដៅក្រហាយដល់អ្នកដទៃ ហើយគិតថា ខ្លួនឯងធ្វើត្រូវគ្រប់ពេលទៀតផង។ ពួកគេមានហេតុផល និងកម្លាំងជម្រុញចិត្តផ្ទាល់ខ្លួន ដែលនាំអ្នកដទៃឱ្យរងទុក្ខវេទនា។ យើងប្រហែលជាឧស្សាហ៍ឃើញមនុស្សប្រភេទនេះនៅតាមសារពត៌មាន ត្រង់ទំព័រ សន្តិសុខសង្គម។ ក្នុងសៀវភៅនេះ យើងមិនលើកសរសើរពីអ្នកដែលធ្វើមិនល្អទេ។

នៅពេលដែលសង្គម មិនជួយផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យមនុស្សមានការឆ្ងល់ អ្នកដែលចេះឆ្ងល់ ក៏ត្រូវបានគេរាប់ជាមនុស្សក្រៅសង្គម។ ការឆ្ងល់ អាចជាផលវិបាកដល់អ្នកដែលគ្រប់គ្រងសង្គម ហេតុនេះគេនឹងធ្វើគ្រប់យ៉ាងដើម្បីកុំឱ្យខ្លួនឯងពិបាក។ មនុស្សក្រៅសង្គមខ្លះ ក៏បានបង្កើតជាប្រយោជន៍ទៅដល់សង្គមរាប់មិនអស់ដែរ គ្រាន់តែមិនសូវមានគេលើកឡើងជាសាធារណៈប៉ុណ្ណោះ។

បើសិនជាយើងមិនឆ្ងល់អ្វីសោះ តើវាចម្លែកប៉ុណ្ណា? ចម្ងល់ ធ្វើឱ្យយើងរីករាយនឹងរស់នៅ។ ចម្ងល់ ធ្វើឱ្យយើងមើលឃើញថា ពិភពលោកនេះ ធំខ្លាំងណាស់ ហើយយើងគ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះ។ ចម្ងល់ អាចក្លាយជាគោលដៅជីវិតរបស់យើងទៀតផង។

គេថា “ភាពងឿងឆ្ងល់ អាចសម្លាប់ឆ្មាបាន” តែយើងមិនមែនជាឆ្មាទេ យើងអាចនឹងដឹងថា អ្វីជារបស់គ្រោះថ្នាក់។ បើយើងឆ្ងល់ពីរឿងផ្លូវភេទរបស់គ្រួសារគេ ហើយទៅលួចមើលគេរាល់យប់ វាអាចក្លាយជាគ្រោះថ្នាក់។ ឬបើយើងឆ្ងល់ពីការរកលុយរបស់អ្នកមានអំណាច ហើយចំណាយពេលតាមដានគេគ្រប់កន្លែង យើងក៏កាន់តែគ្រោះថ្នាក់ដែរ។ បើយើងគ្រាន់តែឆ្ងល់ថា ហេតុអ្វីបានជាមនុស្សចូលចិត្តស្តាប់ចម្រៀង ឬហេតុអ្វីបានយើងរៀនមិនសូវចាំ វាមិននាំគ្រោះថ្នាក់អ្វីមកដល់យើងទេ។ ទាល់តែយើងនៅរស់ ទើបអាចឆ្ងល់បាន ចុះបើយើងឆ្ងល់ រហូតទាល់តែស្លាប់ ឬជិតស្លាប់ តើយើងអាចនឹងឆ្ងល់តាមណាទៀត។

# ការគ្រាប់តាមអ្នកវិទ្យាសាស្ត្រ

គេថា “យើងគ្រប់គ្នាសុទ្ធតែអ្នកវិទ្យាសាស្ត្រ” ព្រោះយើងតែងតែមានចម្ងល់។ ចំណុចដែលខុសគ្នា គឺក្រោយពេលអ្នកវិទ្យាសាស្ត្រមានចម្ងល់ ពួកគេនឹងចាប់ផ្តើមដំណើរការស្វែងរកចម្លើយ ដោយធ្វើការពិសោធន៍តាមបទដ្ឋានវិទ្យាសាស្ត្រ។ អ្នកវិទ្យាសាស្ត្រ នឹងបន្តសួរសំណួរថ្មីៗរហូត ព្រោះនោះជាកិច្ចការរបស់ពួកគេ។ ខ្ញុំគិតថា អ្នកវិទ្យាសាស្ត្រ ជាអ្នកបង្កើតចំណេះដឹង និងដោះស្រាយបញ្ហា ហេតុនេះទើបពួកគេមិនអាចឈប់សួរសំណួរបាន។

អ្នកវិទ្យាសាស្ត្រគ្រប់ផ្នែក ជាមនុស្សដែលពូកែឆ្ងល់។ ពួកគេស្វែងរកចម្លើយគ្រប់ពេលក្នុងគោលបំណងដើម្បីបំពេញចម្ងល់របស់ខ្លួនឯង។ លុយ ក៏ពួកគេស្វែងរកដែរ ព្រោះការស្រាវជ្រាវត្រូវការជំនួយច្រើន។ ចម្ងល់របស់ពួកគេ អាចនាំភាពរីកចម្រើន

ដល់មនុស្សជាតិទាំងមូល។ ការរកឃើញវិធីព្យាបាលជម្ងឺទឹកនោមផ្អែម ជាឧទាហរណ៍មួយដែលបង្ហាញថា ចម្ងល់របស់អ្នកវិទ្យាសាស្ត្រ ជារឿងគួរឱ្យកោតសរសើរ។

ទោះបីយើងមិនមែនជាអ្នកវិទ្យាសាស្ត្រ តែយើងក៏អាចរស់នៅតាមអ្នកវិទ្យាសាស្ត្របានដែរ។ យើងមិនអាចគិតដូចពួកគេមែន ព្រោះយើងមិនបានហាត់រៀនត្រឹមត្រូវដូចពួកគេ ប៉ុន្តែ បើគ្រាន់តែឆ្ងល់ មិនចាំបាច់ត្រូវការសញ្ញាបត្របញ្ជាក់ទេ។ យើងអាចរៀនឆ្ងល់ដោយខ្លួនឯងបាន។ យើងរៀនដោយខ្លួនឯងមែន តែយកក្បួនខ្នាតអនុវត្តន៍ក្នុងផ្នែកវិទ្យាសាស្ត្រមកប្រើ។

ការឆ្ងល់របស់អ្នកវិទ្យាសាស្ត្រ ចាប់ផ្ដើមដោយការសួរសំណួរថា។ នេះជាជំហានទីមួយរបស់អ្នកវិទ្យាសាស្ត្រ។ ក្រោយពេលមានសំណួរហើយ អ្នកវិទ្យាសាស្ត្រ នឹងសរសេរសំណួរទាំងអស់ចេញមក ដើម្បីចាប់ផ្ដើមបង្កើតសម្មតិកម្ម។ សម្មតិកម្ម អាចជាការស្មាន ប៉ុន្តែឈរលើភស្តុតាងដែលមានស្រាប់ណាមួយ។ អ្នកវិទ្យាសាស្ត្រអាចនឹងធ្វើការស្រាវជ្រាវខ្លះមុននឹងចាប់ផ្ដើមបង្កើតសម្មតិកម្ម ដើម្បីកុំឲ្យបង្កើតកំហុសដដែល ឬធ្វើការស្រាវជ្រាវជាន់គ្នា។

សម្មតិកម្ម កើតឡើងដោយលើកជាប្រយោគថា “បើសិនជា... នោះវានឹង..”។ ឧទាហរណ៍ យើងមានសំនួរថា “ហេតុអ្វីបានជាយើងត្រូវខ្វល់ពីកម្រិតនៃភាពឆ្លាតរបស់ខ្លួនឯង (IQ)?” យើងអាចបង្កើតជាសម្មតិកម្មបែបនេះបាន “បើសិនជា IQ អាចជួយសម្រេចគោលដៅ និងភាពរីករាយដល់យើងថ្ងៃអនាគតបាន នោះវានឹងក្លាយជារឿងដែលយើងត្រូវខ្វល់។” វាសមហេតុផល ហើយយើងអាចសាកល្បងធ្វើតេសអ្វីដែលយើងមាននេះបាន។ សម្រាប់អ្នកវិទ្យាសាស្ត្រ ពួកគេនឹងរៀបចំការស្រាវជ្រាវ ដើម្បីដឹងថាសម្មិតកម្មដែលគេមាន ត្រូវឬខុស។

នៅពេលធ្វើតេស អ្នកវិទ្យាសាស្ត្រ នឹងប្រមូលយកទិន្នន័យគ្រប់ប្រភេទ និងកត់ត្រាទុកអ្វីដែលគេសង្កេតឃើញ ដើម្បីធ្វើជាឯកសារស្រាវជ្រាវ។ ក្រោយមក ពួកគេនឹងបញ្ចប់ការស្រាវជ្រាវ ដោយការសន្និដ្ឋានផ្ទាល់ខ្លួន។

ការស្រាវជ្រាវ ត្រូវចំណាយពេលយូរ និងធនធានច្រើន។ ជួនកាល ការស្រាវជ្រាវត្រូវបិទចោលពាក់កណ្ដាលទី បើសិនជាអស់ធនធាន ឬមានកំហុសអ្វីមួយ។ ចុះសម្រាប់យើង? តើយើងមានលទ្ធភាពបែបនេះទេ? តើយើងមានពេលវេលាបែបនេះទេ? កុំភ្លេច ថាយើងមិនមែនជាអ្នកវិទ្យាសាស្ត្រនោះទេ។ យើងគ្រាន់តែខ្ចីវិធីរបស់គេ មកធ្វើឱ្យខ្លួនឯងឆ្ងល់ប៉ុណ្ណោះ។

## ការបើកចិត្តរបស់អ្នកវិទ្យាសាស្ត្រ

មូលហេតុមួយដែលធ្វើឱ្យខ្ញុំជឿលើវិទ្យាសាស្ត្រ ហើយមិនជឿលើសាសនា គឺការបើកចិត្តនេះឯង។ អ្នកវិទ្យាសាស្ត្រ នឹងបើកចិត្តទទួលយកទិន្នន័យថ្មី ឬគំនិតថ្មីគ្រប់ពេល ហើយត្រៀមខ្លួនសម្រាប់ការផ្លាស់ប្ដូរគំនិតខ្លួនឯងរហូត។ អ្នកវិទ្យាសាស្ត្រតែងតែបដិសេធការសន្មតដាច់ខាតរបស់អ្នកដែលមានជំនឿជ្រុល ព្រោះគ្មានអ្វីដែលប្រាកដគ្រប់ពេលទេ។ អ្នកដែលមានជំនឿ មិនគិតបែបនេះទេ។ គេយល់ថា អ្វីដែលពួកគេដឹង ជារឿងត្រឹមត្រូវ ហើយគ្មានអ្វីអាចមកកែប្រែជំនឿគេបានទាំងអស់។ ការគិតគ្រោះថ្នាក់បែបនេះ ជាភស្តុតាងបញ្ជាក់ពីភាពល្ងង់ខ្លៅ។

នៅពេលយើងចេះឆ្ងល់ បានន័យថា យើងបើកចិត្តទទួលយកចម្លើយហើយ ទោះបីចម្លើយនោះមិនដឹងនៅត្រង់ណាក៏ដោយ។ យើងអាចនឹងរកវាឃើញ ឬមិនអាចរកឃើញមួយជីវិត តែវាប្រាកដជាមានចម្លើយ។ យើងបើកចិត្តឱ្យទូលាយ យើងនឹងដឹងថា នៅមានវិធីរកចម្លើយជាច្រើនដែលយើងអាចសាកល្បងបាន។

ខ្ញុំធ្វើការជាមួយគ្រិស្តបរិស័ទ ហើយខ្ញុំទទួលស្គាល់ថា ចំណេះដឹងទាក់ទងនឹងគ្រិស្តសាសនារបស់ខ្ញុំនៅខ្សោយ។ ខ្ញុំក៏សូមគេចូលរៀនដោយមានគ្រូមកពីអង្គការគ្រិស្តសាសនាមកបង្រៀនដល់ក្រុមហ៊ុន។ ខ្ញុំទៅវិហាររបស់គេដើម្បីសុំគម្ពីរគ្រិស្ត មកអានដើម្បីបានស្វែងយល់កាន់តែស៊ីជម្រៅ។ អ្នកដែលធ្វើការជាមួយខ្ញុំ គិតថា ខ្ញុំជឿលើគ្រិស្តសាសនា។ ពួកគេមិនសួរខ្ញុំទេ ព្រោះគេសន្មតថា ខ្ញុំជឿហើយ ទើបខ្ញុំប្រឹងរៀនពីសាសនារបស់គេ។

ខ្ញុំចំណាយពេលរៀន និងអានពីសាសនានេះ ព្រោះខ្ញុំឆ្ងល់ប៉ុណ្ណោះ។ ខ្ញុំចង់ដឹងថា តើគេបង្រៀនពីអ្វីខ្លះ ទើបធ្វើឱ្យមនុស្សងប់ងល់បែបនេះបាន។ សម្រាប់ពុទ្ធសាសនា និងព្រហ្មណ៍សាសនា ខ្ញុំអាចដឹងពីមូលហេតុ ព្រោះខ្ញុំកើតក្នុងប្រទេសខ្មែរ ដែលពោរពេញទៅជំនឿគ្មានហេតុផល។ ការជឿ មិនមែនជាការបើកចិត្តទេ តែវាជាការបិទចិត្ត។ ក្រោយពេលជឿហើយ យើងនឹងលែងឆ្ងល់ លែងសួរអ្វីទាំងអស់។ យើងព្រមទទួលគ្រប់យ៉ាងដែលគេប្រាប់យើង។ គ្រិស្តសាសនាខ្លះ មិនអានគម្ពីរទៀតផង ព្រោះពួកគេមិនចង់ដឹងឱ្យលើសពីអ្វីដែលគេប្រាប់ឱ្យជឿ។

ខ្ញុំជឿលើវិទ្យាសាស្ត្រ ហើយជឿថាវិទ្យាសាស្ត្រ អាចមានកំហុសគ្រប់ពេល។ ខ្ញុំមិនជឿលើសាសនា ព្រោះសាសនា ហាមមិនឱ្យខ្ញុំសួរដេញដោលពីចំណុចមិនសមហេតុផល។ បើខ្ញុំមិនអាចឆ្ងល់ ហើយមិនអាចលើកសំណួរបាន តើខ្ញុំរស់នៅដើម្បីអី? ហេតុអ្វីបានខ្ញុំត្រូវលះបង់ការឆ្ងល់របស់ខ្ញុំ ដើម្បីចូលរួមជាមួយអ្នកដែលមិនចេះឆ្ងល់?

ក្នុងរយៈពេលមួយឆ្នាំដែលខ្ញុំធ្វើការជាមួយពួកគេ ខ្ញុំរៀនបានច្រើនពីសាសនាគ្រិស្ត ជាពិសេសការគិតប្លែករបស់ពួកគេ។ ពួកគេ កាន់សាសនាដូចគ្នា ប៉ុន្តែបកប្រែអ្វីដែលសាសនាបង្រៀនខុសគ្នា។ ពួកគេសំអាងលើគម្ពីរដូចគ្នា តែនិយាយចេញមកខុសគ្នា។ ខ្ញុំអានសៀវភៅដែលគេឱ្យខ្ញុំអានផង និងរកសៀវភៅមកអានដោយខ្លួនឯងទៀត ដើម្បីបំបាត់ចម្ងល់។

សៀវភៅដែលគេឱ្យខ្ញុំអាន ជាសៀវភៅដើម្បីធ្វើឱ្យខ្ញុំជឿ។ សៀវភៅខ្ញុំរកមកអានខ្លួនឯង ជាសៀវភៅដែលធ្វើឱ្យខ្ញុំយល់។ ខ្ញុំគ្មានបំណងជឿ ហេតុនេះទោះបីជាអានប៉ុណ្ណា ក៏ជំនឿវាមិនដុះឡើងដែរ។ ខ្ញុំគ្មានជំនឿពិតមែន តែការឆ្ងល់របស់ខ្ញុំនៅតែមានជានិច្ច។

អ្នកវិទ្យាសាស្ត្របើកចិត្តរៀនសូត្រ ហេតុនេះទើបពួកគេរៀនមិនចេះចប់។ អ្នកដែលបិទចិត្ត រៀនតែបន្តិច ក៏គិតថាខ្លួនឯងចេះ ហើយមានអំណួតលើភាពល្ងង់ខ្លៅរបស់ខ្លួនឯង។ អ្នកទាំងអស់គ្នាអាចមើលគម្រូអ្នកកាន់គ្រិស្តសាសនាបាន។ ពួកគេកាន់តែគម្ពីរមួយក្បាល ហើយជឿថា គម្ពីរនោះមានចម្លើយគ្រប់ទាំងអស់ តាំងពីការកកើតផែនដី និងដំបូន្មានសម្រាប់ការរស់នៅ។ គម្ពីរដែលសរសេរតាំងពីរាប់ពាន់ឆ្នាំមុន ដោយអ្នកដែលមិនស្គាល់ពីវិទ្យាសាស្ត្រ ត្រូវបានពួកគេគិតថា ត្រឹមត្រូវ។ នៅពេលខ្ញុំលឺគេប្រាប់ខ្ញុំថា “ផែនដីមានអាយុ ៦០០០ឆ្នាំ” ខ្ញុំដឹងច្បាស់ថា ខ្ញុំមិនចង់ក្លាយជាសមាជិកផែនដី៦០០០ឆ្នាំបាត់ទៅហើយ។ ដើម្បីរកចម្លើយ ខ្ញុំត្រូវតែបន្តរៀនពីពួកគេទៀត ទោះខ្ញុំមិនឯកភាពក៏ដោយ។

ចំណុចល្អបំផុតរបស់អ្នកវិទ្យាសាស្ត្រ គឺ ពួកគេហ៊ានទទួលស្គាល់ថា ខ្លួនមិនដឹង និងមិនចេះទាំងអស់។ ពេលយើងទទួលស្គាល់ថា យើងមិនទាន់ចេះ ទើបយើងមានចិត្តចង់បាន។

សៀវភៅនេះ មិនមានគោលបំណងលួងលោមអ្នកទាំងអស់គ្នាឱ្យបោះបោលជំនឿបន្តដូនតា ឬជំនឿដែលត្រូវម៉ែឪបង្ខំ ហេតុនេះខ្ញុំមិនលើកឡើងច្រើនពេកទេ។ អ្នកទាំងអស់គ្នា អាចជឿលើអ្វីក៏បានដែរ ឱ្យតែគិតថាល្អសម្រាប់ខ្លួនឯង។ ប៉ុន្តែកុំបោះបោលការឆ្ងល់ ហើយរៀនបើកចិត្តឱ្យទូលាយ។ វាពិបាក នៅពេលដែលយើងមានជំនឿក្នុងខ្លួន ហើយយកវិធីវិទ្យាសាស្ត្រមកប្រើក្នុងការរស់នៅ។ គំនិតរបស់យើងនឹងប្រឆាំងគ្នា តែបើយើងអាចគ្រប់គ្រងវាបាន យើងអាចនឹងបានផលច្រើន។

ខ្ញុំមិនចូលចិត្តជំនឿ តែខ្ញុំអានសៀវភៅសាសនា និងសៀវភៅដែលគេវិភាគពីសាសនា ព្រោះខ្ញុំចេះឆ្ងល់។ ខ្ញុំក៏មិនមែនមានចិត្តទូលាយដែរ តែបើខ្ញុំនិយាយថា ខ្ញុំជឿលើវិទ្យាសាស្ត្រ តែមិនយកការបើកចិត្ត មកធ្វើជាគោលការណ៍ក្នុងការស្វែងរកចម្លើយ ខ្ញុំមិនក្លាយជាមនុស្សដែលបានតែព្រុសទៅហើយ។ ខ្ញុំរៀនបើកចិត្តចំពោះចំណេះដឹងគ្រប់ប្រភេទ តែមិនបើកចិត្តទទួលយកជំនឿទេ។

យើងមិនជឿ យើងរៀនបានច្រើនជាងអ្នកដែលជឿ។ យើងមិនជឿ យើងឆ្ងល់ច្រើនជាងអ្នកដែលជឿ។ យើងមិនជឿ យើងរកឃើញចម្លើយបានច្រើនជាង និងជ្រៅជាងអ្នកដែលជឿ។ ការអានសៀវភៅ ជាវិធីមួយដែលយើងអាចស្វែងរកចម្លើយបានលឿនបំផុត។

រៀនឆ្ងល់ ទើបយើងចេះទទួលយកអ្វីថ្មី។